ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* * *

ឆ្នាំទី ៤ លេខ ៤៧ ថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ១៩៩៦

# រាជកិច្ច

រួមមាន :

- ច្បាប់
- ក្រម-ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្តីសម្រេច
- សារាចរ

ផ្សាយចេញពីទីស្ដីការគណៈរដ្ឋមន្ត្រីរៀងរាល់សប្ដាហ៍

## ក

# មាតិកា

# I ខុទ្ទកាល័យព្រះមហាក្សត្រ

## ១_ ព្រះរាជក្រម


២០.១២.៩៦ ព្រះរាជក្រម នស/រកម/១២៩៦/៣១ ច្បាប់ស្តីពីការអនុម័តយល់ព្រមអោយព្រះរាជាណាចក្រកម្ពុជា ចូលជាសមាជិក សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ ១៩៥៧

២០.១២.៩៦ ព្រះរាជក្រម នស/រកម/១២៩៦/៣២ ច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃឡង់ដ៍ ដើម្បីជំរុញនិងការការពារវិនិយោគ ១៩៥៩

២០.១២.៩៦ ព្រះរាជក្រម នស/រកម/១២៩៦/៣៣ ច្បាប់ស្តីពីការអនុម័តលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរាជរដ្ឋាភិបាលនៃប្រទេសម៉ាឡេស៊ី ដើម្បីជំរុញនិងការការពារវិនិយោគ ១៩៦១


## ២_ ព្រះរាជក្រឹត្យ


១៦.១២.៩៦ ព្រះរាជក្រឹត្យ នស/រកត/១២៩៦/៨៦ តែងតាំងលោក យោគ រាជ ជាលោកអ្នកឧកញ៉ា មានឋានៈស្មើឯកអគ្គរាជទូត ១៩៦៣

១៧.១២.៩៦ ព្រះរាជក្រឹត្យ នស/រកត/១២៩៦/៨៧ តែងតាំងលោក ណា ម៉ារឌី ជា ឧកញ៉ា ១៩៦៤

១៧.១២.៩៦ ព្រះរាជក្រឹត្យ នស/រកត/១២៩៦/៨៨ តែងតាំងលោក ខូវ សម្បត្តិ ជា ឧកញ៉ា ១៩៦៥

១៧.១២.៩៦ ព្រះរាជក្រឹត្យ នស/រកត/១២៩៦/៨៩ តែងតាំងលោក សៀក ពិសិដ្ឋ ជា ឧកញ៉ា ១៩៦៦

១៧.១២.៩៦ ព្រះរាជក្រឹត្យ នស/រកត/១២៩៦/៩០ តែងតាំងលោក ម៉ក់ គឹមហុង ជា ឧកញ៉ា ១៩៦៧

## II ទីស្តីការគណៈរដ្ឋមន្ត្រី

### ១—អនុក្រឹត្យ

១៩.១២.៩៦ អនុក្រឹត្យលេខ ៥២ អនក្រ.បក ស្តីពីបង្កើតរដ្ឋាករទឹកស្វយ័ត ក្រុងភ្នំពេញ ១៩៦៨

### ២—សេចក្តីសំរេច

១៦.១២.៩៦ សេចក្តីសំរេចលេខ ៤៩ សសរ ស្តីពីការជូនប័ណ្ណសរសើរ ១៩៧៩
១៧.១២.៩៦ សេចក្តីសំរេចលេខ ៥០ សសរ ស្តីពីការផ្ទេរសិទ្ធិ ១៩៨៥
២០.១២.៩៦ សេចក្តីសំរេចលេខ ៥១ សសរ ស្តីពីការបង្កើតគណៈកម្មការ អន្តរក្រសួងដើម្បីរៀបចំការងារមហោស្រពអង្គរ ៩៦ «រចាំប្រពៃណី» ១៩៨៦

## III ការងារបណ្តាក្រសួង

### ១—ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និងថាមពល

#### ប្រកាស

១៦.១២.៩៦ ប្រកាសលេខ ៧០២ ផក.ប្រក អនុញ្ញាតអោយលោក ជា វន្ថា ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការឧស្សាហកម្មផលិតទឹក ទឹកកកដើម ១៩៨៨
១៦.១២.៩៦ ប្រកាសលេខ ៧០៣ ផក.ប្រក អនុញ្ញាតអោយលោក លី សុខ ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការសិប្បកម្មផលិតសាច់ ប្រហិត ១៩៨៩

| | | |
|---|---|---|
| ១៦.១២.៩៦ | ប្រកាសលេខ ៧០៤ ផក.ប្រក អនុញ្ញាតអោយលោក ស៊ូ វ៉េង ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការឧស្សាហកម្មតូចផលិតទឹកកកដើម | ១៩៨៩ |
| ១៦.១២.៩៦ | ប្រកាសលេខ ៧០៥ ផក.ប្រក អនុញ្ញាតអោយលោក សុខ ចាប ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការឧស្សាហកម្មតូចផលិតសំបកកង់សញ្ញា « នាគហោះ » | ១៩៩០ |
| ១៦.១២.៩៦ | ប្រកាសលេខ ៧០៦ ផក.ប្រក អនុញ្ញាតអោយលោក ហាង ជា ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការឧស្សាហកម្មតូចផលិតខ្សែចំណងប្លាស្ទិច | ១៩៩០ |
| ១៨.១២.៩៦ | ប្រកាសលេខ ៧០៩ ផក.ប្រក អនុញ្ញាតអោយក្រុមហ៊ុនតៃវ៉ាន់ អូតូ ( TAISUN AUTOMITIVE INDUSTRIES ( CAMBODIA) PTE.LTD តំណាងដោយ លោក RRIAN CHANG សញ្ជាតិសឹង្ហបូរីបង្កើតរោងចក្រ តម្លើងរថយន្តដឹកអ្នកដំណើរ | ១៩៩១ |
| ១៨.១២.៩៦ | ប្រកាសលេខ ៧១០ ផក.ប្រក អនុញ្ញាតអោយក្រុមហ៊ុនតៃវ៉ាន់ ផ្គូតឃីងមីតប្រូសេសស៊ីងផ្លែន ម៉ូទីវ អិនឌីស្ទ្រីខេមបូឌា ( GODKING MEAT PROCESSING PLANT CO.LTD) តំណាង ដោយលោក JUNGFU-CHANG សញ្ជាតិ តៃវ៉ាន់ បង្កើតរោងចក្រផលិត អាហារអំពីសាច់ | ១៩៩១ |
| ២៣.១២.៩៦ | ប្រកាសលេខ ៧១៣ ផក.ប្រក អនុញ្ញាតអោយអ្នកស្រី ងី យ៉េង ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការសិប្បកម្មផលិតដែកគោល | ១៩៩២ |
| ២៣.១២.៩៦ | ប្រកាសលេខ ៧១៤ ផក.ប្រក អនុញ្ញាតអោយលោក លឹម ហុង ឈាង ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការសិប្បកម្មកែច្នៃដើមកៅស៊ូ | ១៩៩៣ |

២៣.១២.៩៦ ប្រកាសលេខ ៧១៥ ផក.ប្រក អនុញ្ញាតអោយអ្នកស្រី ឡាយ នាង ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការឧស្សាហកម្មតូចផលិតទឹកកកដើម ១៩៩៣

២៣.១២.៩៦ ប្រកាសលេខ ៧១៦ ផក.ប្រក អនុញ្ញាតអោយបើកឧស្សាហកម្មតូចផលិតទឹកកកដើមមានលោក បាន គុង ជនជាតិខ្មែរ សញ្ជាតិកម្ពុជា ១៩៩៤

២៣.១២.៩៦ ប្រកាសលេខ ៧១៧ ផក.ប្រក អនុញ្ញាតអោយបើកឧស្សាហកម្មតូចផលិតទឹកកកដើមមានលោក ឈុន អេង ជនជាតិខ្មែរ សញ្ជាតិកម្ពុជា ជាប្រធានបើកដំណើរការឧស្សាហកម្មដំណើរផលិតកម្ម ១៩៩៤

២៣.១២.៩៦ ប្រកាសលេខ ៧១៨ ផក.ប្រក អនុញ្ញាតអោយលោក ថាវ មិញ ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការម៉ាស៊ីនកិនស្រូវកំលាំង ២៤ សេះ ១៩៩៥

២៣.១២.៩៦ ប្រកាសលេខ ៧១៩ ផក.ប្រក អនុញ្ញាតអោយអ្នកស្រី សូ ធីតា ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការឧស្សាហកម្មតូចផលិតទឹកកកដើម ១៩៩៥

២៣.១២.៩៦ ប្រកាសលេខ ៧២០ ផក.ប្រក អនុញ្ញាតអោយអ្នកស្រី ចាង គីមសយ ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការឧស្សាហកម្មតូចផលិតទឹកកកដើម ១៩៩៥


## ២—ទីស្តីការរដ្ឋមន្ត្រីក្រសួងពត៌មាន

### ប្រកាស


១៧.១២.៩៦ ប្រកាសលេខ ៣២៥/៩៦ ពម.ប្រក អនុញ្ញាតជូនលោកស្រី ពុង ប៉េងចេង បើកអាជីវកម្មរោងពុម្ពឈ្មោះ «សារពត៌មានពាណិជ្ជកម្ម» ១៩៩៦

២០.១២.៩៦ ប្រកាសលេខ ៣២៨/៩៦ ពម.ប្រក អនុញ្ញាតជូនលោក Gille Rouxel សញ្ជាតិបារាំងនាំចូលទស្សនាវដ្តីជាភាសាបារាំងឈ្មោះ LE GAVROCHE ១៩៩៨

២០.១២.៩៦ ប្រកាសលេខ ៣៣០/៩៦ ពម.ប្រក អនុញ្ញាតអោយចេញផ្សាយឡើងវិញនូវសារពត៌មាន « អ្នកប្រយុទ្ធ» ១៩៩៩

## ៣—ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

### ប្រកាស

១៧.១២.៩៦ ប្រកាសលេខ ១០១៥ អយក.ប្រក ស្តីពីការប្តូរឈ្មោះអនុវិទ្យាល័យអង្គរជ័យ ទៅជាអនុវិទ្យាល័យ សម្តេច ហ៊ុន សែន «អង្គរជ័យ» ២០០០

## ៤—ទីស្តីការក្រសួងសង្គមកិច្ច ការងារ និង អតីតយុទ្ធជន

### ប្រកាស

១៦.១១.៩៦ ប្រកាសលេខ ៨៩០ សអក ស្តីពីការលុបប្រកាសលេខ ៤៦៤ សកអ ចុះថ្ងៃទី ២១.៥.១៩៩៦ ដែលស្តីពីការតែងតាំងទីប្រឹក្សាក្នុងការបញ្ជូនពលករខ្មែរទៅធ្វើការនៅកោះតៃវ៉ាន់ ២០០២

១៨.១២.៩៦ ប្រកាសលេខ ៨៩៤ សកអ ស្តីពីការឈប់សំរាកថ្ងៃបុណ្យហើយមានប្រាក់ឈ្នួល សំរាប់អ្នកស៊ីឈ្នួលនៃសហគ្រាសគ្រឹស្ថានទាំងអស់ ២០០៤

## ៥—រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

### សេចក្តីសំរេច

២៣.១២.៩៦ សេចក្តីសំរេចលេខ ៧៣៦ សសរ មសក្រខ ស្តីពីការបែងចែកនិស្សិតចំនួន ២២១ ដែលទើបបញ្ចប់ការសិក្សាពីមហាវិទ្យាល័យពាណិជ្ជសាស្ត្រ ២០០៦

# I - ខុទ្ទកាល័យព្រះមហាក្សត្រ

## ១—ព្រះរាជក្រម

ព្រះរាជក្រម នស/រកម/១២៩៦/៣១

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ ព្រះចៅក្រុង

កម្ពុជាធិបតី

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង នាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពី ការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស.រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រីទាំងពីរ និងអំពីទេសរដ្ឋមន្ត្រីទទួលបន្ទុកនីតិសម្បទានិងអភិវឌ្ឍន៍ និងជារដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

# ប្រកាសអោយប្រើ

ច្បាប់ស្តីពី ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាសមាជិកនៃសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦ នាសម័យប្រជុំលើកទី ៧ នីតិកាល ទី ១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ ÷

## ច្បាប់

## ស្តីពី

## ការអនុម័តយល់ព្រមអោយព្រះរាជាណាចក្រកម្ពុជា ចូលជាសមាជិកនៃសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ

**មាត្រា ១** : អនុម័តយល់ព្រមលើកិច្ចព្រមព្រៀងនៃសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ ដែលមានអត្ថបទភ្ជាប់មកជាមួយ និងយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជា ចូលជាសមាជិកនៃសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិនេះ ។

**មាត្រា ២** : អនុម័តយល់ព្រមឱ្យរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ទិញភាគហ៊ុនរបស់សាជីវកម្មនេះជាទឹកប្រាក់ចំនួន បីរយសាមសិបប្រាំបួនពាន់ដុល្លារអាមេរិក (៣៣៩.000USD) ។

**មាត្រា ៣** : រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តនីតិវិធីទាំងឡាយ ដើម្បីបញ្ចូលព្រះរាជាណាចក្រកម្ពុជាជាសមាជិកនៃសាជីវកម្មនេះ ។

**មាត្រា ៤** : ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៦

ព្រះហស្តលេខា

**នរោត្តម សីហនុ**

បានបង្គំទូលថ្វាយ និង ជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រីទី១ និងទី២

ទេសរដ្ឋមន្ត្រីទទួលបន្ទុកនីតិសម្បទា និងអភិវឌ្ឍន៍

និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ហត្ថលេខា

**គាត ឈន់**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ព្រះហស្តលេខា ហត្ថលេខា

**នរោត្តម រណឫទ្ធិ** **ហ៊ុន សែន**

**ព្រះរាជក្រមនស/រកម/១២៩៦/៣២**

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស**

**ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម**

**ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ ព្រះចៅក្រុង**

**កម្ពុជាធិបតី**

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពី ការកែសំរួលសមាសសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស.រកត/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រីទាំងពីរ និងអំពីទេសរដ្ឋមន្ត្រីទទួលបន្ទុកនីតិសម្បទានិងអភិវឌ្ឍន៍ និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## ប្រកាសអោយប្រើ

ច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និង រដ្ឋាភិបាល នៃព្រះរាជាណាចក្រថៃឡង់ដ៍ ដើម្បីជំរុញនិងការពារការវិនិយោគ ដែលរដ្ឋសភាអនុម័តកាលពីថ្ងៃ ទី ៥ ខែ តុលា ឆ្នាំ ១៩៩៦ នាសម័យប្រជុំលើកទី ៧ នីតិកាលទី១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ ÷

# ច្បាប់

## ស្តីពី

## ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជានិង រដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃឡង់ដ៍ ដើម្បីជំរុញនិងការពារការវិនិយោគ

**មាត្រា ១ :** អនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាល នៃព្រះរាជាណាចក្រថៃឡង់ដ៍ ដើម្បីជំរុញនិងការពារការវិនិយោគ ដែលធ្វើនៅបាងកកនៅថ្ងៃទី ២៩ ខែ មិនា ឆ្នាំ ១៩៩៥ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២ :** រាជរដ្ឋាភិបាលកម្ពុជា ត្រូវបន្តនីតិវិធី ដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៦

ព្រះហស្តលេខា

**នរោត្តម សីហនុ**

បានបង្គំទូលថ្វាយ និង ជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រីទី១ និងទី២
ទេសរដ្ឋមន្ត្រីទទួលបន្ទុកនីតិសម្បទា និងអភិវឌ្ឍន៍
និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
ហត្ថលេខា
**គាត ឈន់**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
|---|---|
| ព្រះហស្តលេខា | ហត្ថលេខា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

ព្រះរាជក្រមនស/រកម/១២៩៦/៣៣

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ ព្រះចៅក្រុង

កម្ពុជាធិបតី

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស.រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រីទាំងពីរ និងអំពីទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការនីតិសម្បទានិងអភិវឌ្ឍន៍ និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## ប្រកាសអោយប្រើ

ច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និង រដ្ឋាភិបាល នៃប្រទេស ម៉ាឡេស៊ី ដើម្បីជំរុញនិងការពារការវិនិយោគ ដែលរដ្ឋសភាអនុម័តកាលពីថ្ងៃ ទី ២៨ ខែ តុលា ឆ្នាំ ១៩៩៦ នាសម័យប្រជុំលើកទី ៧ នីតិកាលទី១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ ÷

# ច្បាប់

## ស្តីពី

## ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាល
## នៃព្រះរាជាណាចក្រកម្ពុជានិងរដ្ឋាភិបាលនៃប្រទេសម៉ាឡេស៊ី
## ដើម្បីជំរុញនិងការពារការវិនិយោគ

**មាត្រា ១** : អនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាល នៃប្រទេសម៉ាឡេស៊ី ដើម្បីជំរុញនិងការពារការវិនិយោគ ដែលធ្វើនៅកូឡាឡាំពួរ នាថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ១៩៩៤ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២** :រាជរដ្ឋាភិបាលកម្ពុជា ត្រូវបន្តរាល់នីតិវិធី ដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៦
ព្រះហស្តលេខា
**នរោត្តម សីហនុ**

បានបង្គំទូលថ្វាយ និង ជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រីទី១ និងទី២
ទេសរដ្ឋមន្ត្រីទទួលបន្ទុកនីតិសម្បទា និងអភិវឌ្ឍន៍
និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
ហត្ថលេខា
**គាត ឈន់**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា ហត្ថលេខា
**នរោត្តម រណឫទ្ធិ** **ហ៊ុន សែន**

# ២—ព្រះរាជក្រឹត្យ

ព្រះរាជក្រឹត្យនស/រកត/១២៩៦/៨៦

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន

ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា

តែងតាំង

លោក យោគ រាជ

ជា

លោកអ្នកឧកញ៉ា

មានឋានៈស្មើឯកអគ្គរាជទូត

ធ្វើនៅថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ១៩៩៦

ព្រះហស្តលេខា

នរោត្តម សីហនុ

* * *

ព្រះរាជក្រឹត្យនស/រកត/១២៩៦/៨៧

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន

ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា

តែងតាំង

លោក ណា ម៉ារឌី

ជា

ឧកញ៉ា

ធ្វើនៅថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ១៩៩៦

ព្រះហស្តលេខា

នរោត្តម សីហនុ

* * *

**ព្រះរាជក្រឹត្យនស/រកត/១២៩៦/៨៨**

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន**

**ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា**

**តែងតាំង**

**លោក ខូវ សម្បត្តិ**

**ជា**

**ឧកញ៉ា**

**ធ្វើនៅថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ១៩៩៦**

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

* * *

ព្រះរាជក្រឹត្យនស/រកត/១២៩៦/៨៩

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន

ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា

តែងតាំង

លោក សៀក ពិសិដ្ឋ

ជា

ឧកញ៉ា

ធ្វើនៅភ្នំពេញ ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ១៩៩៦

ព្រះហស្តលេខា

នរោត្តម សីហនុ

* * *

ព្រះរាជក្រឹត្យនស/រកត/១២៩៦/៩០

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន

ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា

តែងតាំង

លោក ម៉ក់ គឹមហុង

ជា

ឧកញ៉ា

ធ្វើនៅថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ១៩៩៦

ព្រះហស្តលេខា

នរោត្តម សីហនុ

* * *

# II - ឯកសារគណៈរដ្ឋមន្ត្រី

## ១_អនុក្រឹត្យ

*រាជធានីភ្នំពេញ , ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ១៩៩៦*

**អនុក្រឹត្យលេខ ៥២ អនក្រ.បក**

**ស្តីពីការបង្កើត**

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**

**(រ.ទ.ស.ភ)**

**រាជរដ្ឋាភិបាល**

–បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

–បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២

–បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា

–បានឃើញព្រះរាជក្រមលេខ ០២ នស ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

–បានឃើញព្រះរាជក្រឹត្យលេខ នស រកត ១០៩៤–៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ និង ព្រះរាជក្រឹត្យលេខ នស រកត ១០៩៤–៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

–បានឃើញព្រះរាជក្រមលេខ នស រកម ០១៩៦–០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

–បានឃើញព្រះរាជក្រមលេខ នស រកម ០១៩៦–១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

–បានឃើញព្រះរាជក្រមលេខ ០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦ ស្តីពីលក្ខន្តិកៈ ទូទៅនៃសហគ្រាសសាធារណៈ

–តាមសំណើរបស់ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

–គណៈរដ្ឋមន្ត្រីយល់ព្រមផង

## សំរេច

## ជំពូកទី១

## បទបញ្ញត្តិទូទៅ

**មាត្រា ១ :** រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ( **រ.ឋ.ស.ភ**) ជាគ្រឹះស្ថានសាធារណៈមួយមានឧបនិស្ស័យសេដ្ឋកិច្ចតាមន័យរបស់មាត្រា២៦ នៃព្រះរាជក្រមលេខ ០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ ១៩៩៦ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ ។ **រ.ឋ.ស.ភ**ជានីតិបុគ្គលប្រកបដោយស្វ័យភាព ផ្នែករដ្ឋបាល និងផ្នែកហិរញ្ញវត្ថុ ។

**រ.ឋ.ស.ភ** ស្ថិតនៅក្រោមអាណាព្យាបាលនៃសាលាក្រុងភ្នំពេញ ហើយមានទីស្នាក់ការនៅរាជធានីភ្នំពេញ ។

**រ.ឋ.ស.ភ** ត្រូវស្ថិតនៅក្រោមឥទ្ធិពលបទបញ្ញត្តិនៃអនុក្រឹត្យនេះ ហើយក្នុងករណីដែល អនុក្រឹត្យនេះពុំបានបញ្ជាក់ការគ្រប់គ្រងនៃ **រ.ឋ.ស.ភ** ត្រូវគោរពតាមបទបញ្ញត្តិ នៃព្រះរាជក្រម លេខ ០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាស សាធារណៈ ព្រមទាំងតាមបទបញ្ញត្តិនៃច្បាប់ពាណិជ្ជកម្ម ។

**មាត្រា ២ :** **រ.ឋ.ស.ភ** មានបេសកកម្ម ផលិត និង ចែកចាយទឹក សំរាប់ការប្រើប្រាស់ទូទៅនៃសាធារណជននៅទីក្រុងភ្នំពេញ ។

ដើម្បីបំពេញបេសកកម្មនេះ **រ.ឋ.ស.ភ** ត្រូវអនុញ្ញាតអោយធ្វើកិច្ចប្រតិបត្តិការគ្រប់ជំពូក លើអចលនវត្ថុ ព្រមទាំងផ្នែកពាណិជ្ជកម្ម និងហិរញ្ញវត្ថុជាអាទិ៍ ÷

–ការផលិត និងការចែកចាយទឹកទូទៅក្នុងរាជធានីភ្នំពេញ ឬ នៅទីប្រជុំជនជុំវិញទីក្រុង ភ្នំពេញ ។

-ការពង្រីក ការបង្កើន និងការស្តារឡើងវិញនូវប្រព័ន្ធផលិត និងបណ្តាញចែកចាយទឹក

-ការធ្វើអាជីវកម្មលើបណ្តាញចែកចាយទឹក ដែលមានស្រាប់ ឬ ដែលត្រូវបង្កើត ។

**មាត្រា ៣ :** ភ្នាក់ងារ **រ.ឱ.ស.ភ** មានសិទ្ធិចេញចូលក្នុងទីកន្លែងសាធារណៈ ឬ ទីលំនៅឯកជនតាមតំរូវការងាររបស់ខ្លួនជាអាទិ៍ ដើម្បីធ្វើការតំឡើង និងជួសជុលបំពង់ទឹកការត្រួតពិនិត្យផ្នែកបច្ចេកទេស គ្រឿងម៉ាស៊ីនផលិតកម្ម និងបណ្តាញចែកចាយទឹកហើយនឹងការកត់ស្រង់នូវបរិមាណទឹកដែលបានប្រើប្រាស់ ។

ភ្នាក់ងារ **រ.ឱ.ស.ភ** ទាំងនេះត្រូវមានសំលៀកបំពាក់សំគាល់ និងត្រូវកាន់ប័ណ្ណអាជីវកម្ម យថាភូតភ្ជាប់នឹងខ្លួន ។

**មាត្រា ៤ :** ក្នុងកិច្ចប្រតិបត្តិការរបស់ខ្លួន **រ.ឱ.ស.ភ** ត្រូវប្រកាន់គោលការណ៍ និងរបៀបប្រកបកិច្ចការដូចគ្នា នឹងពាណិជ្ជករទូទៅ ។ ក្នុងន័យនេះ **រ.ឱ.ស.ភ** ត្រូវទទួលស្វយ័តភាពយ៉ាងធំទូលាយ ដើម្បីដឹកនាំចាត់ចែងសកម្មភាពរបស់ខ្លួនក្នុងគោលដៅបំពេញបេសកកម្មរបស់ខ្លួនអោយមានប្រសិទ្ធភាព និងធ្វើយ៉ាងណាអោយបេតិកភ័ណ្ឌរបស់ខ្លួនបានគង់វង្ស និងមានការរីកចំរើន ។

**មាត្រា ៥ :** **រ.ឱ.ស.ភ** ត្រូវបង់ពន្ធអាករទាំងឡាយ ស្របតាមច្បាប់ និងបទបញ្ញាជាធរមាន ។

**មាត្រា ៦ :** ដើមទុនដំបូងរបស់ **រ.ឱ.ស.ភ** ត្រូវកំណត់ដោយបញ្ជីតុល្យការដំបូង ដែលបានទទួលការឯកភាពពីក្រសួងសេដ្ឋកិច្ច ហិរញ្ញវត្ថុ សាលាក្រុងភ្នំពេញ និង **រ.ឱ.ស.ភ** ។

ចាប់ពីពេលដែលអនុក្រឹត្យនេះចូលជាធរមាន **រ.ឱ.ស.ភ** ត្រូវចាត់ទុកជាម្ចាស់កម្មសិទ្ធិពេញច្បាប់ជំនួសរដ្ឋ លើទ្រព្យសម្បត្តិទាំងអស់ ដែលមានកត់ត្រាក្នុងបញ្ជីសារពើភ័ណ្ឌ ។

**មាត្រា ៧ :** បុគ្គលិករបស់ **រ.ឱ.ស.ភ** ត្រូវគ្រប់គ្រងដោយលក្ខន្តិកៈដោយឡែកអនុម័តដោយក្រុមប្រឹក្សាភិបាល ។

ទំរាំមានលក្ខន្តិកៈដោយឡែកនេះ ក្រុមប្រឹក្សាភិបាល **រ.ឱ.ស.ភ** នឹងសំរេចអំពីអន្តរវិធាន ដែលទាក់ទងនឹងបញ្ហានេះនៅក្នុងកិច្ចប្រជុំលើកទី១របស់ខ្លួន ដើម្បីអោយសហគ្រាសអាចមានដំណើរការប្រពៃសមស្រប ។

ចាប់ពីពេលដែលលក្ខន្តិកៈដោយឡែក នេះចូលជាធរមាន បុគ្គលិករបស់ **ទ.ឧ.ស.គ** លែងមានលក្ខណសម្បត្តិជាមន្ត្រីរាជការរបស់រដ្ឋតទៅទៀត ។

## **ជំពូកទី២**

## **រចនាសម្ព័ន្ធវិស័យរដ្ឋបាល**

**មាត្រា ៨ :** **ទ.ឧ.ស.គ** ត្រូវគ្រប់គ្រងដោយក្រុមប្រឹក្សាភិបាល ដែលមានសមាជិកដូចខាងក្រោមនេះ ÷

- តំណាងសាលាក្រុងភ្នំពេញ ...... ១ រូប
- តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ...... ១ រូប
- តំណាងក្រសួងមហាផ្ទៃ ...... ១ រូប
- តំណាងក្រសួងឧស្សាហកម្មរ៉ែ និងថាមពល ...... ១ រូប
- តំណាងក្រសួងសាធារណការនិងដឹកជញ្ជូន ...... ១ រូប
- តំណាងនិយោជិករបស់ **ទ.ឧ.ស.គ** ...... ១ រូប
- អគ្គនាយក **ទ.ឧ.ស.គ** ...... ១ រូប

តំណាងសាលាក្រុងភ្នំពេញមានមុខងារជាប្រធាននៃក្រុមប្រឹក្សាភិបាល ។

សមាជិកក្រុមប្រឹក្សាភិបាលត្រូវចាត់តែងតាំងដោយអនុក្រឹត្យ តាមសំណើនៃក្រសួង ឬ អាជ្ញាធរដែលខ្លួនតំណាងអោយ ។

តំណាងនិយោជិកត្រូវជ្រើសរើសដោយបោះឆ្នោត ក្នុងចំណោមនិយោជិករបស់ **ទ.ឧ.ស.គ** ។

**មាត្រា ៩ :** សមាជិកក្រុមប្រឹក្សាភិបាលត្រូវមានសញ្ជាតិជាខ្មែរ មានសិទ្ធិរដ្ឋប្បវេណីពេញលេញពុំដែលទទួលទណ្ឌកម្មមានកំរិតធ្ងន់ពីតុលាការឡើយ ។ លើសពីនេះទៅទៀត សមាជិកក្រុមប្រឹក្សាភិបាលទាំងអស់នោះ ត្រូវជ្រើសរើសក្នុងចំណោមមន្ត្រីសកម្មដែលបានបំរើការយ៉ាងតិច ៥ឆ្នាំ ឬ ឥស្សរជន ពុំមែនជាមន្ត្រីរាជការដែលមានអាយុមិនលើសពី ៦៥ ឆ្នាំ តែមានបទពិសោធន៍គ្រប់គ្រាន់ និង ជំនាញខ្ពស់ក្នុងវិស័យសេដ្ឋកិច្ចវិទ្យាសាស្ត្រ ឬ នីតិសាស្ត្រ ។

អាណត្តិសមាជិកក្រុមប្រឹក្សាភិបាល មានថិរៈវេលា៣ឆ្នាំ ហើយថិរវេលានេះអាចបន្តជាថ្មីទៀតបាន ។

ក្នុងការបំពេញអាណត្តិរបស់ខ្លួន សមាជិកក្រុមប្រឹក្សាភិបាលពុំទទួលការខុសត្រូវផ្ទាល់ខ្លួនម្នាក់ៗ ឬការទទួលខុសត្រូវរួមគ្នាទេ ។ ក្នុងករណីដែលសមាជិកណាម្នាក់មានកំហុសធ្ងន់ធ្ងរ សមាជិករូបនោះអាចត្រូវដកចេញពីមុខងាររបស់ខ្លួនគ្រប់ពេលវេលាដោយអនុក្រឹត្យ ។

**មាត្រា១០ :** ក្រុមប្រឹក្សាភិបាលមានសិទ្ធិពេញលេញ ដើម្បីសំរេចក្នុងនាមនៃ **រ.ឧ.ស.គ** និងដើម្បីបំពេញ ឬ អនុញ្ញាតលិខិត និងឯកសារគ្រប់ជំពូក ទាក់ទងនឹងកម្មវត្ថុរបស់សហគ្រាសស្របតាមច្បាប់ជាធរមាន ។

ជាអាទិ៍ក្រុមប្រឹក្សាភិបាលមាននាទី ៖

១) ផ្តល់ការយល់ព្រម លើគំរោងសហគ្រាស ដូចមានចែងនៅក្នុងមាត្រា ១៩ នៃអនុក្រឹត្យនេះ ។

២) វាយតំលៃរៀងរាល់ពេលវេលា ដែលបានកំណត់ទុកមុនរួចហើយនូវលទ្ធផលដែលបានគ្រោងទុក ហើយចាត់វិធានការដើម្បីកែសំរួលអោយស្របតាមសភាពការណ៍ ។

៣) ផ្តល់ការយល់ព្រមលើតុល្យការនិងគណនីប្រចាំឆ្នាំ ព្រមទាំងលើរបាយការណ៍សកម្មភាពរបស់សហគ្រាស ។

៤) សំរេចតាមសំណើ នៃអគ្គនាយកនូវរចនាសម្ព័ន្ធ និងបទបញ្ជាផ្ទៃក្នុងរបស់សហគ្រាស ព្រមទាំងលក្ខន្តិកៈ និងកាំប្រាក់បៀវត្សសំរាប់បុគ្គលិក ដោយគោរពច្បាប់ និងបទបញ្ញត្តិទាំងឡាយជាធរមាន ។

៥) ផ្តល់ការយល់ព្រមលើកិច្ចសន្យា និងអនុសញ្ញា ដែល **រ.ឧ.ស.គ** ជាភាគីស្របតាមលក្ខខ័ណ្ឌ និងបែបបទ ដូចមានគ្រោងក្នុងបទបញ្ជាជាធរមានស្តីពីកិច្ចសន្យា និងអនុសញ្ញា ដែលចុះដោយសហគ្រាសសាធារណៈ ។

៦) អនុញ្ញាតអោយលក់ ទិញ ផ្លាស់ប្តូរ អចលនទ្រព្យគ្រប់ប្រភេទ ឬភាគហ៊ុនព្រម ទាំងអនុញ្ញាតការខ្ចីបុលកំឡុងកាល មធ្យម ឬ វែង ដោយ **រ.ឧ.ស.គ** ស្របតាមច្បាប់ និងបទបញ្ជាទាំងឡាយជាធរមាន ។

៧) សំរេចបង្កើតបើក បិទការិយាល័យ និងទីភ្នាក់ងារគ្រប់ទីកន្លែង តាមការវិនិច្ឆ័យរបស់ខ្លួន ។

មាត្រា ១១ : ក្រុមប្រឹក្សាភិបាលបើកប្រជុំរាល់ៗវេលា អាស្រ័យតាមអត្ថប្រយោជន៍នៃសហគ្រាស តាមការអញ្ជើញរបស់ប្រធាន ឬ តាមសំណើនៃសមាជិក ដែលមានចំនួនបួននាក់យ៉ាងតិចក្នុងបណ្តាសមាជិកទាំងអស់ ។ ទោះយ៉ាងណាក៏ដោយ កិច្ចប្រជុំត្រូវធ្វើឡើងយ៉ាងតិចមួយដងក្នុងរយៈពេលបីខែ។

ប្រធានដែលជាប់ធុរៈ ត្រូវជ្រើសរើសសមាជិកម្នាក់ ក្នុងបណ្តាសមាជិកក្រុមប្រឹក្សាភិបាល សំរាប់បំពេញភារៈកិច្ចជំនួយប្រធានជាបណ្តោះអាសន្ន ។

ក្រុមប្រឹក្សាភិបាលពិភាក្សាលើបញ្ហាទាំងឡាយដែលចូលក្នុងក្របខ័ណ្ឌនៃតួនាទីរបស់ខ្លួន ។ របៀបវារៈនៃការប្រជុំ ព្រមទាំងឯកសារទាក់ទិនទាំងឡាយត្រូវផ្ញើជូនសមាជិកក្រុមប្រឹក្សាភិបាលគ្រប់រូប និង «មន្ត្រីត្រួតពិនិត្យរដ្ឋ» អោយបានយ៉ាងតិច ១០ ថ្ងៃមុនពេលបើកអង្គប្រជុំ ។

កិច្ចប្រជុំនៃក្រុមប្រឹក្សាភិបាលអាចប្រព្រឹត្តបាន លុះត្រាតែចំនួន សមាជិកវត្តមាន ក្នុង សម័យប្រជុំនោះមានចំនួនយ៉ាងតិចពាក់កណ្តាលនៃបណ្តាសមាជិកទាំងអស់ ។ បើសិនជាចំនួនកូរ៉ុមមិនបានគ្រប់ទេ ក្រុមប្រឹក្សាភិបាលត្រូវកោះប្រជុំជាថ្មីម្តងទៀត ក្នុងរយៈពេល ១៥ ថ្ងៃក្រោយ ដើម្បីពិភាក្សាសំរេចឡើងវិញលើបញ្ហាតាមរបៀបវារៈដដែល ។ កិច្ចប្រជុំលើកក្រោយនេះ មិន ទាមទារកូរ៉ុមទេ ។

សេចក្តីសំរេចទាំងឡាយរបស់ក្រុមប្រឹក្សាភិបាលអាចយកជាការបាន លុះត្រាតែមានការ អនុម័តដោយសម្លេងភាគច្រើន នៃសមាជិកវត្តមាននៅក្នុងអង្គប្រជុំ ។ បើសិនការបែកសម្លេងមានចំនួនស្មើ ពុំអាចដាច់ស្រេចបានសម្លេងប្រធានមានអាទិភាពលើសម្លេងសមាជិកដទៃទៀត ។

មាត្រា ១២ : សេចក្តីសំរេចនៃក្រុមប្រឹក្សាភិអាលត្រូវកត់ត្រាក្នុងកំណត់ហេតុមួយ ដែលត្រូវបញ្ជូនទៅអាជ្ញាធរអាណាព្យាបាល ទៅសមាជិកក្រុមប្រឹក្សាភិបាលម្នាក់ៗ និង «មន្ត្រីត្រួតពិនិត្យរដ្ឋ» និងគោលដៅ ដទៃទៀត ដែលមានចែងក្នុងមាត្រា២៥ ខាងក្រោម ក្នុងរវាង១៥ថ្ងៃ យ៉ាងយូរ ចាប់រាប់ពីថ្ងៃប្រជុំ។

កំណត់ហេតុនៃកិច្ចប្រជុំ ត្រូវទទួលការយល់ព្រមពីក្រុមប្រឹក្សាភិបាលនាសម័យប្រជុំលើកក្រោយហើយត្រូវចំឡងចូលបញ្ជី ដែលមានលេខរៀងទំព័រជាហូរហែ និងមានហត្ថលេខាចំណាំត្រឹមត្រូវ ។ កំណត់ហេតុដើម ត្រូវមានចុះ

ហត្ថលេខាដោយប្រធាននៃអង្គប្រជុំ និងសមាជិកក្រុម ប្រឹក្សាភិបាលណាម្នាក់ដែលមានវត្តមានក្នុងកិច្ចប្រជុំពេលមុននោះ ។

**មាត្រា ១៣ :** អគ្គនាយកមានភារកិច្ចជាអ្នកគ្រប់គ្រងប្រក្រតីនៃ **រ.ឧ.ស.គ** ។ អគ្គនាយកនេះត្រូវតែងតាំងសំរាប់អាណត្តិ ៣ ឆ្នាំ ដោយអនុក្រឹត្យ តាមសំណើនៃអាជ្ញាធរអាណាព្យាបាល ។

**មាត្រា ១៤ :** ក្រុមប្រឹក្សាភិបាលប្រគល់ជូនអគ្គនាយក នូវអំណាចចាំបាច់សំរាប់ដំណើរការប្រចាំថ្ងៃ ដើម្បីមានលទ្ធភាពគ្រប់គ្រាន់សំរាប់ដឹកនាំសហគ្រាសស្របតាមច្បាប់ និងការណែនាំរបស់ក្រុមប្រឹក្សាភិបាល។

ក្នុងក្របខ័ណ្ឌនេះ អគ្គនាយក ÷

១–ជាអ្នករៀបចំសំណុំរឿងទាំងឡាយ ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាល និងជាអ្នកចាត់ចែងការអនុវត្តន៍រាល់សេចក្តីសំរេចរបស់ក្រុមប្រឹក្សាភិបាល ។ តាមកំណត់ពេលនិមួយៗ អគ្គនាយកត្រូវរាយការណ៍ ជូនក្រុមប្រឹក្សាភិបាលអំពីសកម្មភាពរបស់ **រ.ឧ.ស.គ** ។

២–ទទួលបន្ទុកដឹកនាំ **រ.ឧ.ស.គ** ផ្នែកបច្ចេកទេស រដ្ឋបាល និង ហិរញ្ញវត្ថុ ។

៣–តំណាងសហគ្រាសចំពោះមុខតតិយជនទាំងឡាយ ក្នុងការបំពេញលិខិតស្នាក់ស៊ីវិលរដ្ឋបាល ឬ លិខិតតុលាការក្នុងក្របខ័ណ្ឌច្បាប់ និងការសំរេចរបស់ក្រុមប្រឹក្សាភិបាល ។

៤–មានសិទ្ធិជ្រើសរើសតែងតាំងដកហូតតំណែង ឬ បញ្ឈប់ពីការងារមានសិទ្ធិបញ្ជាត្រួតត្រា នូវភ្នាក់ងារ ឬ មន្ត្រីគ្រប់រូបដែលជានិយោជិករបស់ **រ.ឧ.ស.គ** ដោយគោរពតាមបទបញ្ញត្តិលក្ខន្តិកៈបុគ្គលិក តាមច្បាប់ជាធរមាន និងតាមការសំរេចរបស់ក្រុមប្រឹក្សាភិបាល ។

៥–មានសិទ្ធិផ្ទេរអំណាចមួយភាគ ឬ ទាំងអស់ ព្រមទាំងផ្ទេរសិទ្ធិចុះហត្ថលេខាទៅអោយមន្ត្រី ដែលធ្វើការក្រោមឱវាទខ្លួន ស្របតាមល័ក្ខខ័ណ្ឌដែលកំណត់ដោយក្រុមប្រឹក្សាភិបាល ។

៦–ជាសរុបអគ្គនាយកជាអ្នកអនុវត្តនូវគ្រប់ភារកិច្ច ដែលក្រុមប្រឹក្សាភិបាលប្រគល់អោយ ។

**មាត្រា ១៥ :** លាភការរបស់អគ្គនាយក និងប្រាក់បំណាច់សំរាប់សមាជិកក្រុមប្រឹក្សាភិបាល ត្រូវកំណត់ដោយអាជ្ញាធរអាណាព្យាបាល និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមសំណើរបស់ក្រុមប្រឹក្សាភិបាល ។

**មាត្រា ១៦ :** ការចុះ និងការអនុវត្តកិច្ចសន្យាដោយ **រ.ឧ.ស.គ** ត្រូវគោរពតាមបែបបទ និង និតិវិធី ដែលកំណត់ដោយច្បាប់ជាធរមាន ។

## ជំពូក ៣

## ការគ្រប់គ្រងហិរញ្ញវត្ថុ

**មាត្រា ១៧ :** **រ.ឧ.ស.គ** កាន់គណនេយ្យរបស់ខ្លួន ដោយប្រើតួលេខជាប្រាក់រៀលស្រប តាមបទបញ្ជាគណនេយ្យកម្ពុជា និងតាមវិធាន នៃគណនេយ្យ ដែលគេទទួលស្គាល់ជាទូទៅ ។ រយៈការិយបរិច្ឆេទ គណនេយ្យ ចាប់ផ្តើមពីថ្ងៃទី ១មករា ហើយ បញ្ចប់នៅថ្ងៃទី ៣១ ធ្នូ នៃឆ្នាំដដែល ។

តុល្យការ និងគណនីគ្រប់គ្រង ត្រូវកំណត់ទូទាត់ដោយក្រុមប្រឹក្សាភិបាល មុនថ្ងៃ ៣០ ខែ មិនា នៃឆ្នាំបន្ទាប់ឆ្នាំបិទការិយបរិច្ឆេទ ឈរលើរបាយការណ៍ នៃគណនេយ្យករជំនាញម្នាក់ ដែល មានមុខងារជាស្នងគណនី ។

តុល្យការគណនីគ្រប់គ្រង ព្រមទាំងរបាយការណ៍របស់ស្នងការគណនី ត្រូវដាក់សុំការយល់ ព្រមអំពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងកំឡុងវេលាមិន លើសពី ១៥ ថ្ងៃរាប់ពីថ្ងៃដែលក្រុម ប្រឹក្សាភិបាលបានពិនិត្យឯកសារទាំងឡាយ ។ ឯកសារទាំងនេះក៏ត្រូវបញ្ជូន ទៅអាជ្ញាធរអាណាព្យាបាលផងដែរ ដើម្បីសុំមតិ ទៅតាមលក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា ១៦ នៃព្រះរាជក្រម លេខ ០៦៩៦/០៣ ចុះថ្ងៃទី ១៧ មិថុនា ឆ្នាំ ១៩៩៦ ស្តីពីលក្ខន្តិកៈ នៃសហគ្រាសសាធារណៈ ។

**មាត្រា ១៨ :** ស្នងការគណនីត្រូវតែងតាំងដោយក្រុមប្រឹក្សាភិបាលសំរាប់អាណត្តិ ២ឆ្នាំចិរ វេលានេះអាចបន្តទៀតបាន ។ ប្រាក់បំណាច់សំរាប់ស្នងការគណនី ត្រូវកំណត់ដោយ ក្រុមប្រឹក្សាភិបាលហើយ ត្រូវចាត់ទុកជាចំណាយអាជីវកម្មរបស់ **រ.ឧ.ស.គ** ។

ស្នងការគណនីត្រូវធ្វើរបាយការណ៍មួយ ដើម្បីបញ្ជាក់ថា គណនីប្រចាំឆ្នាំនៃការិយបរិច្ឆេទមានភាពស្មោះត្រង់ និងត្រឹមត្រូវល្អ ហើយឆ្លុះបញ្ចាំងអំពីភាពពិតប្រាកដ នៃស្ថានភាពហិរញ្ញវត្ថុ និងបេតិកភ័ណ្ឌរបស់ **រ.ឧ.ស.គ** ។

នៅគ្រប់វេលា ស្នងការគណនី អាចធ្វើការផែកឆេរ និងការត្រួតពិនិត្យ ដែលខ្លួនយល់ថា ចាំបាច់គួរតែត្រូវពិនិត្យ ថែមទាំងអាចទារឯកសារ និងបញ្ជីគណនេយ្យគ្រប់យ៉ាងសំរាប់ធ្វើការត្រួតពិនិត្យ ។ បើការពិនិត្យស្រាវជ្រាវនេះ បង្ហាញអោយឃើញភាពមិនត្រឹមត្រូវណាមួយស្នងការគណនីត្រូវរាយការណ៍ ភ្លាមជូនប្រធានក្រុមប្រឹក្សាភិបាល ។

ស្នងការគណនីអាចចូលប្រជុំជាមួយក្រុមប្រឹក្សាភិបាលបាន តាមសេចក្ដីអញ្ជើញនៃប្រធានក្រុមប្រឹក្សាភិបាល ។

**មាត្រា ១៩ :** រៀងរាល់ឆ្នាំមុនថ្ងៃ ១ ខែ តុលា ក្រុមប្រឹក្សាភិបាលត្រូវផ្ដល់ការយល់ព្រមលើគំរោងសហគ្រាសប្រចាំឆ្នាំ តាមសំណើរបស់អគ្គនាយក ហើយបញ្ជូនគំរោងនេះ ដើម្បីសុំការអនុម័តពីរដ្ឋមន្ត្រីអាណាព្យាបាល និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

គំរោងសហគ្រាសនេះត្រូវបញ្ជាក់នូវ ÷

១–កម្មវិធីវិនិយោគ ព្រមទាំង ហិរញ្ញប្បទានបំរុងសំរាប់សំរេចកម្មវិធីវិនិយោគនេះ

២–ថវិកាសំរាប់ដំណើរការនៃសហគ្រាស

៣–តម្លៃលក់ទឹក និងតម្លៃលក់សេវាកម្មផ្សេងៗរបស់ **រ.ឧ.ស.ត** ទៅអតិថិជន ដើម្បីសហគ្រាសអាចមានលទ្ធភាពទប់ទល់ នឹងសោហ៊ុយដែលមានគិតបញ្ចូលនូវប្រាក់រំលស់ទុនវិនិយោគ និង អាចធានាសមតាហិរញ្ញវត្ថុរបស់ខ្លួនបាន

៤–លក្ខណៈវិនិច្ឆ័យសំរាប់វាស់វែងលទ្ធផលសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរបស់ **រ.ឧ.ស.ត** ។

៥–វិភាគទានទាំងឡាយដែលរដ្ឋអាចផ្ដល់ជូន **រ.ឧ.ស.ត** ដើម្បីជ្រោមជ្រែងការបង់ខាតចំពោះសេវាសាធារណៈ ដែលសហគ្រាសបានផ្ដល់សំរាប់បំរើអត្ថប្រយោជន៍របស់ពលរដ្ឋ ។

**មាត្រា ២០ :** ធនធាននៃ **រ.ឧ.ស.ត** ជាអាទិ៍មាន ÷

–ប្រាក់ដើមទុនដែលរដ្ឋផ្ដល់អោយ

–វិភាគទាន ឬ ប្រាក់ឧបត្ថម្ភដែលបានមកពីរដ្ឋ និងសមូហភាពសាធារណៈផ្សេងៗ

-ប្រាក់ឧបត្ថម្ភដែលបានមកពីរាជរដ្ឋាភិបាល ឬ អំណោយ ស្ម័គ្រចិត្តពីឯកជន ដោយមានការ ទទួលព្រមព្រៀងជាបឋមពីក្រុមប្រឹក្សាភិបាល ។

-ប្រាក់ខ្ចីបុល

-ប្រាក់ចំណូលផ្សេងៗគ្រប់ប្រភេទបានមកពីសកម្មភាពសហគ្រាស

-ប្រាក់បានមកពីការលក់ ឬ ជួលទ្រព្យចលនវត្ថុ ឬ អចលនវត្ថុ

មាត្រា២១ : ចំណាយនៃ ស.ឧ.ស.ត ជារួមមាន :

-ចំណាយប្រក្រតី សំរាប់ដំណើរការ

-ចំណាយវិនិយោគ

-សំណងបំណុល

-សោហ៊ុយផ្សេងៗដែល ស.ឧ.ស.ត ត្រូវចំណាយដើម្បីបំពេញបេសកកម្មរបស់ខ្លួន ។

មាត្រា ២២ : ស.ឧ.ស.ត អាចមានគណនីចរន្ត ក្នុងធនាគារពាណិជ្ជកម្មផ្សេងៗ ហើយប្រើប្រាស់គណនីនេះ សំរាប់តំរូវការរបស់ខ្លួន ។

មាត្រា ២៣ : ក្នុងរយៈពេល៥ឆ្នាំ ឬ លើសពីនេះ បើមានការសំរេចពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុប្រាក់ចំណេញដែល ស.ឧ.ស.ត ទទួលបានក្រោយពីការទូទាត់ស្របតាមវិធាន ។

មាត្រា ២៣ : ក្នុងរយៈពេល៥ឆ្នាំ ឬ លើសពីនេះ បើមានការសំរេចពីរដ្ឋមន្ត្រី ក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុប្រាក់ចំណេញដែល ស.ឧ.ស.ត ទទួលបានក្រោយពីការទូទាត់ស្រប តាមវិធានការគណនេយ្យដែលគេ ទទួលស្គាល់ជាទូទៅ ត្រូវបញ្ចូលទៅក្នុងគណនីមូលនិធិបំរុងមួយ ដើម្បីពង្រឹងលទ្ធភាពហិរញ្ញវត្ថុរបស់ ស.ឧ.ស.ត ។

មាត្រា ២៤ : ការខ្ចីបុលកំឡុងកាលមធ្យម ឬ វែងដោយ ស.ឧ.ស.ត សំរាប់ប្រើប្រាស់លើចំណាយវិនិយោគ ត្រូវមានការយល់ព្រមជាមុន ពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

## ជំពូក ៤

## ការទំនាក់ទំនងជាមួយរដ្ឋ

### មាត្រា២៥

**មាត្រា ២៥ :** ១៥ថ្ងៃ យ៉ាងយូរបំផុត ក្រោយពីការអនុវត្តរបស់ក្រុមប្រឹក្សាភិបាល **រ.ឧ.ស.គ** ត្រូវផ្ញើជូនរដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីអាណាព្យាបាល និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុ នូវឯកសារដូចខាងក្រោមនេះ ÷

–កំណត់ហេតុ នៃកិច្ចប្រជុំក្រុមប្រឹក្សាភិបាលនីមួយៗ

–គំរោងសហគ្រាស ដូចមានចែងក្នុងមាត្រា ១៩ នៃអនុក្រឹត្យនេះ

–របាយការណ៍ស្តីពីសកម្មភាពគុណ្យការ និង គណនីគ្រប់គ្រងទាំងឡាយនៃ **រ.ឧ.ស.គ**

–របាយការណ៍ស្តីពីការត្រួតពិនិត្យរបស់ស្នងការគណនី

**មាត្រា ២៦ :** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្នើរដ្ឋាភិបាលតែងតាំងមន្ត្រីត្រួតពិនិត្យរដ្ឋម្នាក់អម **រ.ឧ.ស.គ** ។ មន្ត្រីរូបនេះចូលរួមគ្រប់កិច្ចប្រជុំនៃក្រុមប្រឹក្សាភិបាល ហើយអាចផ្តល់យោបល់លើគ្រប់ចំណុចទាំងឡាយដែលមានក្នុងរបៀបវារៈ តែពុំមានសម្លេងឆ្នោតទេ ។ «មន្ត្រីត្រួតពិនិត្យរដ្ឋ» បំពេញបេសកកម្មរបស់ខ្លួន អនុលោមតាមបទបញ្ញត្តិ នៃមាត្រា២០ ទៅ២៥ នៃព្រះរាជក្រម លេខ ០៦៩៦/០៣ ចុះថ្ងៃទី ១៧ មិថុនា ១៩៩៦ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ ។

**មាត្រា ២៧ :** **រ.ឧ.ស.គ** មានសិទ្ធិផ្អាក ឬ ផ្តាច់ការផ្គត់ទឹក ឬ សេវាដទៃទៀត ចំពោះអតិថិជនឯកជន ឬ អង្គភាពសាធារណៈណាមួយ ដែលមិនបង់ថ្លៃទឹកទៅអោយ **រ.ឧ.ស.គ** ក្នុងរយៈវេលាដែលបាន កំណត់ក្នុងកិច្ចសន្យាជាវទឹក ។

## ជំពូកទី ៥

## អវសានបញ្ញត្តិ

**មាត្រា ២៨ :** ការទំនាក់ទំនងរវាង **រ.ឧ.ស.គ** និងអតិថិជនព្រមទាំងអំពើល្មើសច្បាប់ទាំងឡាយពីសំណាក់ អតិថិជន ដែលប៉ះពាល់ដល់សហគ្រាស ជាពិសេសការបំបាត់ចំនួនទឹកដែលត្រូវបានប្រើប្រាស់ ការបំផ្លិចបំផ្លាញ ឬ ការគេងប្រវ័ញ្ចវត្ថុ

ដែលជាកម្មសិទ្ធិរបស់ **រ.ឧ.ស.ត** ការលួចតបណ្ដាញទឹកដោយគ្មានការអនុញ្ញាត ។ល។ ត្រូវស្ថិតនៅក្រោមច្បាប់ និងបទបញ្ញាទាំងឡាយជាធរមាន ។

**មាត្រា ២៩ :** សហរដ្ឋមន្ត្រីទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុប្រតិភូរាជរដ្ឋាភិបាល ប្រចាំក្រុងភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និងចុះហត្ថលេខាតទៅ ។

បានបង្គំទូលថ្វាយ និងជំរាបជូន
សម្ដេចនាយករដ្ឋមន្ត្រីទី១ និងទី២
ទេសរដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រី
ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
ហត្ថលេខា
**គាត ឈន់**

នាយករដ្ឋមន្ត្រីទី១
ព្រះហស្ថលេខានិងត្រា
**នរោត្តម រណឫទ្ធិ**

នាយករដ្ឋមន្ត្រីទី២
ហត្ថលេខានិងត្រា
**ហ៊ុន សែន**

* * *

# ២_សេចក្ដីសំរេច

រាជធានីភ្នំពេញ,ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ១៩៩៦

**សេចក្ដីសំរេច លេខ ៤៩ សសរ**

**ស្ដីពីការជូនបំណ្ណសរសើរ**

* * *

រាជរដ្ឋាភិបាល

– បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
– បានឃើញព្រះរាជក្រឹត្យរបស់ ព្រះករុណាព្រះបាទ សម្ដេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
– បានឃើញច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-បានឃើញស្នាដៃរបស់កងឯកភាព និង នាយទាហានក្នុងការបំពេញភារកិច្ច ការពារសុវត្ថិភាព ជូនសម្តេច នាយករដ្ឋមន្ត្រីទី២ ។

**សម្រេច**

**ប្រការ១** : ត្រូវបានប្រគល់បណ្ណសរសើរ ជូន អង្គភាព ចំនួន ៣៧ និង បុគ្គលចំនួន ១៥១ រូប ដែលមានស្នាដៃល្អប្រសើរ ក្នុងការបំពេញភារកិច្ចជូនអង្គភាព ដូចមានរាយនាមខាងក្រោម ÷

**ខ—បុគ្គល** :

| | | | |
|---|---|---|---|
| ១ | ម៉ៅ សុផាន់ | ឧត្តមសេនីយ៍ត្រី | មេបញ្ជាការកងពលតូចលេខ ៧០ |
| ២ | ហែម ថា | វរសេនីយ៍ឯក | មេបញ្ជាការរងកងពលតូចលេខ ៧០ |
| ៣ | សេង សុង | = | មេបញ្ជាការរងកងពលតូចលេខ ៧០ |
| ៤ | ពិន ណារិទ្ធ | = | អាកាសយានិក |
| ៥ | ចាប ភក្តី | = | មេបញ្ជាការវរសេនាធំ ៩១១ ឆ័ត្រយោង |
| ៦ | សុខ ខៀង | វរសេនីយ៍ទោ | មេបញ្ជាការវរសេនាធំ ៩១១ ឆ័ត្រយោង |
| ៧ | ស្រី សុផល | = | នាយសេនាធិការកងពលតូចលេខ ៧០ |
| ៨ | សុខ សុវណ្ណ | = | មេបញ្ជាការរងកងឯកភាពអង្គរក្ស |
| ៩ | អ៊ុង សារិទ្ធ | = | នាយរងសេនាធិការ កងឯកភាពអង្គរក្ស |
| ១០ | អាន ចាន់សារឿន | = | = |
| ១១ | សោម ជន | = | = |
| ១២ | គង់ វណ្ណា | = | = |
| ១៣ | ព្រាប លីណា | = | បើកបររថយន្តសម្តេច |
| ១៤ | នួន ណារិន | = | នាយផ្នែកហិរញ្ញវត្ថុ អង្គរក្ស |
| ១៥ | ទេព សុភារី | វរសេនីយ៍ត្រី | អាកាសយានិក |
| ១៦ | ទុន សុខុន | = | នាយផ្នែកលេខាធិការដ្ឋាន |
| ១៧ | ចឹក កាន | = | នាយរងផ្នែកលេខាធិការដ្ឋាន |
| ១៨ | លឹម សុធា | = | នាយផ្នែកបញ្ជាការដ្ឋាន |
| ១៩ | នៅ ស៊ីណាត | = | មេបញ្ជាការបញ្ជូនសារ |
| ២០ | សុខ ភាសនា | = | នាយរងផ្នែកហិរញ្ញវត្ថុ |

| | | | | |
|---|---|---|---|---|
| ២១ | សោម | សុតិថិរ៉ា | = | នាយការិយាល័យទី១ |
| ២២ | ហែម | រិទ្ធី | = | នាយរងការិយាល័យទី១ |
| ២៣ | អ៊ួង | ចំណាន | = | នាយការិយាល័យទី២ |
| ២៤ | ស្រី | សារ៉េត | = | នាយរងការិយាល័យទី២ |
| ២៥ | រស់ | សារ៉ាវិទ្ធ | = | = |
| ២៦ | ឡៀង | សារុន | = | នាយការិយាល័យទី៣ |
| ២៧ | ឡេង | សំអឿន | = | នាយរងការិយាល័យទី៣ |
| ២៨ | យ៉ាត | វិត | = | នាយរងការិយាល័យទី៣ |
| ២៩ | តង់ | តារី | = | នាយការិយាល័យទី៤ |
| ៣០ | ម៉ែន | រុន | = | នាយរងការិយាល័យទី៤ |
| ៣១ | ខិន | ទី | = | នាយរងការិយាល័យទី៤ |
| ៣២ | ភិន | សាបាន | = | នាយរងការិយាល័យទី៤ |
| ៣៣ | តន់ | ហេង | វរសេនីយ៍ត្រី | នាយរងការិយាល័យទី៤ |
| ៣៤ | នឹង | ឃាង | = | នាយរងការិយាល័យទី៤ |
| ៣៥ | រឿង | វុទ្ធី | = | នាយការិយាល័យទី៥ |
| ៣៦ | សំ | សៀន | = | ជំនួយការការិយាល័យទី៤ |
| ៣៧ | ទេព | សែម | = | មេបញ្ជាការកងអនុសេនាធំ រថយន្ត |
| ៣៨ | អាត់ | សុខេម | = | ពេទ្យអង្គរក្ស |
| ៣៩ | ឌឹម | សារី | = | នាយផ្នែកប្រេងឥន្ធនៈ |
| ៤០ | អ៊ុក | អ៊ុន | = | នាយរងផ្នែកប្រេងឥន្ធនៈ |
| ៤១ | ចាន់ | ញ៉ៀ | = | មេបញ្ជាការរងវរសេនាតូចលេខ ២៤៦ |
| ៤២ | ទិត្យ | យ៉ន | = | មេបញ្ជាការរងវរសេនាតូចលេខ ២៤៦ |
| ៤៣ | យូ | សារ៉ាន | = | មេបញ្ជាការរងវរសេនាតូចលេខ ២៤៦ |
| ៤៤ | ព្រហ្ម | ពន្លឺ | = | នាយសេនាធិការវរៈ ២៤៦ |
| ៤៥ | ប៉ែន | ចាន់ | = | មេបញ្ជាការរងវរអន្តរាគមន៍ |
| ៤៦ | យ៉ន | ផារ៉ា | = | = |
| ៤៧ | កើត | ចន | = | = |

| | | | |
|---|---|---|---|
| ៤៨ | រ៉េត ស៊ីថា | = | នាយសេនាធិការរងអន្តរាគមន៍ |
| ៤៩ | អ៊ុំ សំអាត | | មេបញ្ជាការរងវរៈ ៥៩៤ |
| ៥០ | ឈិន សុវណ្ណ | = | = |
| ៥១ | លីវ វណ្ណថុល | = | = |
| ៥២ | ឡុច សុខា | = | មេបញ្ជាការកងអនុសេនាធំលេខ ៩ |
| ៥៣ | ឃួន សាមិត្ត | = | បំរើការផ្ទាល់ |
| ៥៤ | ស៊ិន ហួរ | = | = |
| ៥៥ | នៅ សារ៉ុន | = | បើកបររថយន្តសម្តេច |
| ៥៦ | គុប សំអន | = | មេបញ្ជាការកងអនុសេនាធំ ម៉ូតូ |
| ៥៧ | ជិន ណាគ្រី | = | មេបញ្ជាការកងអនុសេនាធំ ម៉ូតូស |
| ៥៨ | ស៊ិន សិន | = | ការពារផ្ទាល់ |
| ៥៩ | លី រ័ត្នសុខា | = | = |
| ៦០ | ជា លន | = | មេបញ្ជាការកងអនុសេនាធំ ការពារផ្ទាល់ |
| ៦១ | ភាព រញ្ញា | = | មេបញ្ជាការកងការពារ |
| ៦២ | ហែល ហាន | = | មេបញ្ជាការរងការពារផ្ទាល់ |
| ៦៣ | កែវ សុភី | = | = |
| ៦៤ | ឆាយ សារ៉េត | = | នាយសេនាធិការ ការពារផ្ទាល់ |
| ៦៥ | វង្ស តារា | អនុសេនីយ៍ឯក | បច្ចេកទេសអាកាសយានិក |
| ៦៦ | កែវ កេន | = | នាយរងការិយាល័យទី ៤ |
| ៦៧ | ហែម ដារា | = | នាយរងការិយាល័យទី ២ |
| ៦៨ | លិន សុផល | = | = |
| ៦៩ | ងី សំណាង | = | លេខាធិការ |
| ៧០ | យិន ចាន់ធួន | = | ជំ.ប្រយុទ្ធវរសេនាតូច ៥៩៤ |
| ៧១ | ទេព សេដ្ឋា | = | នាយផ្នែកសុខាភិបាល |
| ៧២ | ធី សម្បត្តិ | = | ពេទ្យ |
| ៧៣ | ប៉ែន គឿន | អនុសេនីយឯក | នាយផ្នែកយន្តយុទ្ធ |
| ៧៤ | សៀប ឆាត | = | នាយផ្នែកអគ្គិសនី |
| ៧៥ | លឹម សារឿន | = | មេបញ្ជាការរងបញ្ជូនសារ |

| | | | |
|---|---|---|---|
| ៧៦ | ឈឹម វាសនា | | នាយរងហិរញ្ញវត្ថុ |
| ៧៧ | ននួ និន | = | |
| ៧៨ | កុក គី | = | សារពតិមាន |
| ៧៩ | ង៉ី ទូច | = | = |
| ៨០ | សេង នីលីន | | = |
| ៨១ | សំ សុគន្ធា | = | បើកបររថយន្ត សាឡែន |
| ៨២ | ឃួន វណ្ណា | = | បើកបររថយន្ត |
| ៨៣ | ផុត សុផាត | = | = |
| ៨៤ | សែម សោភ័ណ្ឌ | = | |
| ៨៥ | គឹម វន្ថា | | = |
| ៨៦ | ស៊ុំ ចំរើន | = | |
| ៨៧ | សួន សុខរ៉ា | = | = |
| ៨៨ | យឹប កូយ្ឃ | = | មេបញ្ជាការកងអនុសេនាធំការពារ |
| ៨៩ | យ៉ង់ សារឿន | = | មេបញ្ជាការកងអនុសេនាតូចការពារផ្ទាល់ |
| ៩០ | ភ័ក្ក ភិរុន | = | សេនាធិការ ការពារផ្ទាល់ |
| ៩១ | ជុំ ចេត | = | ការពារផ្ទាល់ |
| ៩២ | ឃ្លួញ សត្ថម៉ា | = | = |
| ៩៣ | ស សារ៉ាន់ | = | = |
| ៩៤ | អ៊ុក សុផាត | = | = |
| ៩៥ | ម៉ែន សុខ | = | = |
| ៩៦ | ចាន់ សុផល | = | = |
| ៩៧ | សុខ សាវុធ | = | = |
| ៩៨ | ឌីប សុវណ្ណឌី | = | = |
| ៩៩ | ហួត សាចាន | = | មេបញ្ជាការកងអនុសេនាធំគាំទ្រ |
| ១០០ | មុំ គឹមអឿន | = | មេបញ្ជាការកងអនុសេនាធំរថក្រោះ |
| ១០១ | សេក សៀងហៃ | = | មេបញ្ជាការ រថពាសដែក |
| ១០២ | ឃ្លាំង ថង | = | ប៉េ អ៊ឹម ២ |
| ១០៣ | សេក សារឿន | = | ប៉េ អ៊ឹម ១ |

| | | | |
|---|---|---|---|
| ១០៤ | អ៊ុក សំ | = | លេខ ១០ |
| ១០៥ | ឯល វណ្ណថន | = | លេខ ១១ |
| ១០៦ | សំ សាមឿន | = | លេខ ១២ |
| ១០៧ | ចាន់ តាំ | អនុសេនីយ៍ឯក | មេបញ្ជាការរង កងអនុសេនាធំលេខ ១២ |
| ១០៨ | ផាន់ សាមន | អនុសេនីយ៍ឯក | មេបញ្ជាការ កងអនុសេនាធំលេខ ៨ |
| ១០៩ | សុខ ឡុង | អនុសេនីយ៍ឯក | មេបញ្ជាការរង កងអនុសេនាធំលេខ ៨ |
| ១១០ | រស់ សាធ | អនុសេនីយ៍ឯក | មេបញ្ជាការរងកងអនុសេនាធំលេខ ៨ |
| ១១១ | សំ សាន្ត | អនុសេនីយ៍ឯក | មេបញ្ជាការរងកងអនុសេនាធំលេខ ៩ |
| ១១២ | សេង ស៊ឿប | អនុសេនីយ៍ឯក | មេបញ្ជាការរងកងអនុសេនាធំម៉ូតូ |
| ១១៣ | ង៉ែត សោភ័ណ្ឌ | អនុសេនីយ៍ឯក | មេបញ្ជាការរងកងអនុសេនាធំលេខ ១១ |
| ១១៤ | ខាត់ សំបិន | អនុសេនីយ៍ឯក | មេបញ្ជាការរងកងអនុសេនាធំ គាំទ្រ |
| ១១៥ | ឡេង គឿន | អនុសេនីយ៍ឯក | មេបញ្ជាការរងកងអនុសេនាធំលេខ ១២ |
| ១១៦ | ព្រាប សារិន | អនុសេនីយ៍ឯក | ប្រធានក្រុម អ្នូប័រ |
| ១១៧ | កុល រ៉ាវី | អនុសេនីយ៍ឯក | បើកបរអ្នូប័រ |
| ១១៨ | ឃួន សុគន្ធ | អនុសេនីយ៍ឯក | បើកបរអ្នូប័រ |
| ១១៩ | គឹម ពៅ | អនុសេនីយ៍ឯក | ជំនួយការលេខាធិការដ្ឋាន |
| ១២០ | យ៉ាត ទូច | អនុសេនីយ៍ឯក | ជំនួយការលេខាធិការដ្ឋាន |
| ១២១ | កែវ អេង | អនុសេនីយ៍ឯក | ជំនួយការ ហិរញ្ញវត្ថុ |
| ១២២ | ម៉ាន់ សូផារី | អនុសេនីយ៍ឯក | ជំនួយការទូរលេខសំងាត់ |
| ១២៣ | ភ័ក្រ វណ្ណឌី | អនុសេនីយ៍ទោ | ជំនួយការទូរលេខសំងាត់ |
| ១២៤ | ប្រាក់ ចិន្តា | អនុសេនីយ៍ទោ | ជំនួយការទូរលេខសំងាត់ |
| ១២៥ | នូ ប្រុសពៅ | អនុសេនីយ៍ទោ | ជំនួយការផ្នែករដ្ឋបាល |
| ១២៦ | មាស សម្បត្តិ | អនុសេនីយ៍ទោ | កងអនុសេនាធំ គាំទ្រ |
| ១២៧ | គុជ ម៉ានិន | អនុសេនីយទោ | បញ្ជាការរងរថពាសដែក |
| ១២៨ | ឡៀវ សុគន្ធារី | អនុសេនីយ៍ឯក | បញ្ជាការរងរថពាសដែក |
| ១២៩ | ញ៉ឹក ញ៉ូក់ | អនុសេនីយ៍ទោ | បញ្ជាការរងរថពាសដែក |
| ១៣០ | សូ សុវន្នា | អនុសេនីយ៍ទោ | បញ្ជាការរងរថពាសដែក |
| ១៣១ | មុំ សុផល | អនុសេនីយ៍ទោ | បញ្ជាការរងរថក្រោះ |

| | | | |
|---|---|---|---|
| ១៣២ | សយ សាបាន | អនុសេនីយ៍ទោ | បញ្ជាការរងរថក្រោះ |
| ១៣៣ | លឹម សុធី | អនុសេនីយ៍ទោ | បញ្ជាការរងរថក្រោះ |
| ១៣៤ | សុខ គីមអេង | អនុសេនីយ៍ទោ | បញ្ជាការរងកងអនុសេនាធំ ១១ |
| ១៣៥ | អ៊ុំ សុផាត | អនុសេនីយ៍ទោ | បញ្ជាការរង ម៉ូតូប្រដេញ |
| ១៣៦ | ឃ្លោក ម៉េន | អនុសេនីយ៍ទោ | បញ្ជាការរង តាំទ្រ |
| ១៣៧ | ហួត ណារ៉ុ | អនុសេនីយ៍ទោ | បញ្ជាការរង ១០ |
| ១៣៨ | យី ឆៃយ៉ា | អនុសេនីយ៍ទោ | បញ្ជាការរង ១១ |
| ១៣៩ | នូ ណារ៉ាន់ដា | អនុសេនីយ៍ទោ | ជំនួយការហិរញ្ញវត្ថុ |
| ១៤០ | ម៉ី ថារី | អនុសេនីយ៍ត្រី | ជំនួយការ យន្តយុទ្ធ |
| ១៤១ | ស៊ឹង ស៊ីថា | អនុសេនីយ៍ត្រី | ជំនួយាការ យន្តយុទ្ធ |

**ប្រការ២** : សហរដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវអនុវត្តសេចក្តីសំរេចនេះអោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី២

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ១៩៩៦

**សេចក្តីសំរេចលេខ ៥០ សសរ**

**ស្តីពីការផ្ទេរសិទ្ធិ**

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែង តាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

-បានឃើញច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-តាមសំណើរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

**សំរេច**

**ប្រការ ១** : តែងតាំងឯកឧត្តម **ស៊ុំ ម៉ានិត** រដ្ឋលេខាធិការទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ជំនួសឯកឧត្តម **ប្រាក់ សុខ** រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈដែលត្រូវអញ្ជើញទៅប្រទេសបារាំង ដើម្បីចូលរួមប្រជុំអំពីការងាររដ្ឋបាលសាធារណតាមរបៀបបារាំង ចាប់ពីថ្ងៃទី ០៥ ខែធ្នូ ឆ្នាំ ១៩៩៦ រហូតដល់ឯកឧត្តមបញ្ចប់បេសកម្ម ។

**ប្រការ ២** : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និង ឯកឧត្តម **ស៊ុំ ម៉ានិត** ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខានេះតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី១ | នាយករដ្ឋមន្ត្រីទី២ |
| ព្រះហស្តលេខានិងត្រា | ហត្ថលេខានិងត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៦

**សេចក្តីសំរេចលេខ ៥១ សសរ**

**សេចក្តីសំរេច**

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញសេចក្តីជូនដំណឹងលេខ១២៦៧សជណ.អរ ចុះថ្ងៃទី ២៩ ខែ ១១ ឆ្នាំ ១៩៩៦ របស់ទីស្តីការគណៈរដ្ឋមន្ត្រីស្តីពីការអនុញ្ញាតយល់ព្រម អោយក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ រៀបចំមហោស្រពអង្គរ ៩៦ « របាំប្រពៃណី » នៅខេត្តសៀមរាប ។
- យោងតាមសំណើរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ចុះថ្ងៃទី ៩ ខែ ធ្នូ ឆ្នាំ ១៩៩៦

**សំរេច**

**ប្រការ ១** : បង្កើតគណៈកម្មការអន្តរក្រសួងមួយ ដើម្បីរៀបចំការងារមហោស្រពអង្គរ ៩៦ « របាំប្រពៃណី » ដែលប្រព្រឹត្តទៅ នៅថ្ងៃទី២១ ដល់ថ្ងៃទី ២៣ ខែធ្នូ ឆ្នាំ ១៩៩៦ នៅខេត្តសៀមរាប

**ប្រការ ២** : គណៈកម្មការអន្តរក្រសួងនេះរួមមានសមាសភាពដូចខាងក្រោម ÷

១-ឯកឧត្តម **នុត ណារ៉ាង** រដ្ឋមន្ត្រីក្រសួង វប្បធម៌ និងវិចិត្រសិល្បៈ ប្រធាន

២-អ្នកអង្គម្ចាស់ **ស៊ីសុវត្ថិ សេរីវុធ ប៉ាណារ៉ា** រដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ អនុប្រធាន

៣-ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬតំណាង អនុប្រធាន

៤- ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងទេសចរណ៍ ឬតំណាង អនុប្រធាន

៥-ឯកឧត្តម **ទន់ ចាយ** អភិបាលខេត្ត សៀមរាប អនុប្រធាន

៦-ឯកឧត្តម **ម៉ែន យ៉េត** អនុរដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ អនុប្រធានអចិន្ត្រៃយ៍

៧-លោក **ពេជ្រ ទុំក្រវិល** អគ្គនាយក អភិវឌ្ឍន៍វប្បធម៌និងវិចិត្រសិល្បៈ នៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ សមាជិក

៨-លោក **ឌុយ តៀន** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ សមាជិក

៩–លោក **ឈុប គួន** អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុនៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សមាជិក

ប្រការ ៣ : គណៈកម្មការ អន្តរក្រសួងនេះមានភារកិច្ចសំរបសំរួលជាមួយក្រសួងដែលពាក់ព័ន្ធក្នុងការប្រព្រឹត្តិទៅនៃមហោស្រព និងរាយការណ៍អំពីលទ្ធផលនៃដំណើរការមហោស្រពជូនរាជរដ្ឋាភិបាលជ្រាបជារបាយការណ៍ ។

ប្រការ ៤ : សហរដ្ឋមន្ត្រីទទួលបន្ទុក ទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រី ប្រធានស្ថាប័នដែលមានការពាក់ព័ន្ធត្រូវអនុវត្តតាមសេចក្តីសំរេចនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី១ | នាយករដ្ឋមន្ត្រីទី២ |
| ព្រះហស្តលេខានិងត្រា | ហត្ថលេខានិងត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

# III - ការងារបណ្តាក្រសួង

## ១–ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

## ប្រកាស

### ប្រកាសលេខ ៧០២ ឧក.ប្រក ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយលោក **ខាវ ចន្ថា** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ៣១៤១២២ ភ.ព ចុះថ្ងៃទី ២៦ - ៤ - ៩១ អាស័យដ្ឋានបច្ចុប្បន្នផ្លូវលេខ ២ អឺ១ ផ្លូវលេខ ១៨៣ សង្កាត់ទំនប់ទឹក ខ័ណ្ឌចំការមន រាជធានីភ្នំពេញ បន្តដំណើរឧស្សាហកម្មតូចផលិតទឹកកកដើមនៅក្នុងទីតាំងផ្ទះលេខ៥៤-៥៦ ផ្លូវលេខ១៥៦ ក្រុមទី១៥ សង្កាត់ផ្សារដេប៉ូទី១ ខ័ណ្ឌទួលគោក រាជធានី ភ្នំពេញ ។

ប្រការ ២ : ប្រកាសនោះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្ត

ល្មើសច្បាប់ផលិតផលគ្មានគុណភាព ប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មាន សំណាងឡើយ ។

* * *

**ប្រកាសលេខ ៧០៣ ផក.ប្រក.ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ១៩៨៦**

**ប្រការ ១** : អនុញ្ញាតអោយលោក **លី សុខ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០១២៩៧៧ ក.ណ ចុះថ្ងៃទី ១៤ - ១២ - ៨៤ អាស័យដ្ឋានបច្ចុប្បន្នផ្ទះលេខ ២៣២ ផ្លូវលេខ ១៥០ សង្កាត់ទឹកល្អក់ទី២ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ បន្តដំណើរការសិប្បកម្មផលិត សាច់ប្រហិត នៅក្នុងទីតាំងដូចអាស្រ័យដ្ឋានខាងលើ

**ប្រការ២** : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ផលិតផលគ្មានគុណភាព ប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណាងឡើយ ។

* * *

**ប្រកាសលេខ ៧០៤ ផក.ប្រក.ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ១៩៨៦**

**ប្រការ ១** : អនុញ្ញាតអោយលោក **ស៊ូ ទ៉េង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០១៥០០៨ ភ.ព ចុះថ្ងៃទី ១៥ - ១២ - ៨៤ អាស័យដ្ឋានបច្ចុប្បន្នផ្ទះលេខ ២៧២អ៊ី០ ផ្លូវម៉ៅសេទុង សង្កាត់បឹងសាឡាង ខ័ណ្ឌទួលគោក រាជធានីភ្នំពេញបន្តដំណើរការឧស្សាហកម្មតូចផលិត ទឹកកកដើមនៅក្នុងទី តាំងដីឡូត៍លេខ ៣០ ផ្លូវលេខ១៦០ ក្រុមទី១៥ សង្កាត់បឹងកក់ទី ២ ខ័ណ្ឌទួល គោករាជធានីភ្នំពេញ ។

**ប្រការ ២** : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ផលិតផលគ្មានគុណភាព ប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ

ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

**ប្រកាសលេខ ៧០៥ ឧក. ប្រក. ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ១៩៩៦**

**ប្រការ ១** : អនុញ្ញាតអោយលោក **សុខ ថាច** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ១៩៨៤៣៤ ភ.ព ចុះថ្ងៃទី ០៧- ៣ - ៨៩ អាស័យដ្ឋានបច្ចុប្បន្នផ្ទះលេខ ៦៣ អឺ០ ផ្លូវលេខ ១១៨ សង្កាត់ផ្សារចាស់ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ បន្តដំណើរការឧស្សាហកម្មតូចផលិតសំបកកង់សញ្ញា «នាគហោះ » នៅក្នុងទីតាំងដីឡូត៍លេខ ១៧៩ ផ្លូវលេខ៣៥៧ ភូមិកណ្តាល សង្កាត់ច្បារអំពៅទី ២ ខ័ណ្ឌមានជ័យរាជធានីភ្នំពេញ ។

